01196289

002/19-09-2007-ECCC/TC
**E1/374**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de recep on): 25 / 01 / 2016
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

ថ្ងៃ អង្គារ ទី ១២ ខែ មករា ឆ្នាំ ២០១៦

**សវនាការលើភ័ស្តុតាង - ថ្ងៃ ៣៥៥**

រៀបចំដោយ៖ ជា ស៊ីវហ៊ាង និង Evelyn CAMPOS SANCHEZ

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Claudia FENZ, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា, ចៅក្រម យ៉ា សុខន |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ កញ្ញា ជា ស៊ីវហ៊ាង , លោកស្រី Evelyn CAMPOS SANCHEZ |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Vincent DE WILDE D'ESTMAEL, លោក សេង លាង, កញ្ញា សុង ឆវិន្ត, លោក Dale LYSAK |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក សុន អរុណ, លោក លីវ សុវណ្ណា |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |

| |
|---|
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD, លោក វ៉ែន ពៅ |
| សាក្សី៖ មុយ វ៉ាន់នី (2-TCW-987), សយ ខឿន (2-TCW-988) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, លោកស្រី ស្វ សុធាវី |
| ផ្សេងៗ៖ កញ្ញា ស្រី ណាក់, លោក ឡូញ ង៉ែត, លោកស្រី សំ មករា, កញ្ញា សុក សុភ័គមណីកា, លោក Mr Lachlan SLATTERY |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៦ | ចាប់ផ្ដើមម៉ោង៖ ០៩.០៤ | បញ្ចប់ម៉ោង៖ ១៥.៣២ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ០៩.៥៤ | បញ្ចប់ម៉ោង៖ ១០.១២ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១១.៤២ | បញ្ចប់ម៉ោង៖ ១៣.៣៤ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.៤២ | បញ្ចប់ម៉ោង៖ ១៥.០១ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៣ ម៉ោង និង ៥៩ នាទី |

| **កិច្ចដំណើរការនីតិវិធីផ្សេងទៀត** | | | |
|---|---|---|---|
| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០៤ | ០៩.០៦ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្ដី នួន ជា | ០៩.០៦ | ០៩.០៧ |
| ការបន្តតាំងសំណួរទៅកាន់សាក្សី មុយ វ៉ាន់នី (2-TCW-987) | មេធាវីការពារក្ដី ខៀវ សំផន | ០៩.០៨ | ០៩.៥៤ |
| ការតាំងសំណួរទៅកាន់សាក្សី សយ ខឿន (2-TCW-988) | អង្គជំនុំជម្រះ<br>សហព្រះរាជអាជ្ញា<br><br><br>មេធាវីការពារក្ដី ខៀវ សំផន<br><br>សហព្រះរាជអាជ្ញា | ១០.១២<br>១០.២៣<br>១១.៣៨<br>១៣.៣៥<br>១៣.៤៧<br>១៥.២៥<br>១៣.៥១ | ១០.២៣<br>១១.២៩<br>១១.៤១<br>១៣.៣៧<br>១៣.៥១<br>១៥.៣០<br>១៤.១៤ |

| | | | |
|---|---|---|---|
| | មេធាវីការពារក្តី នួន ជា | ១៤.១៥ | ១៤.៤២ |
| | | ១៥.០១ | ១៥.០៦ |
| | អង្គជំនុំជម្រះ | ១៥.០៦ | ១៥.២៥ |
| សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំប្រើប្រាស់ឯកសារ E319/19.3.226 នៅក្នុងសវនាការ | សហព្រះរាជអាជ្ញា | ១១.២៩ | ១១.៣១ |
| | | ១១.៣៤ | ១១.៣៥ |
| | | ១៣.៣៧ | ១១.៣៨ |
| | អង្គជំនុំជម្រះ | ១១.៣២ | ១១.៣២ |
| | | ១១.៣៦ | ១១.៣៧ |
| | | ១១.៣២ | ១១.៣២ |
| | | ១១.៣៨ | ១៣.៤៧ |
| | មេធាវីការពារក្តី ខៀវ សំផន | ១១.៣៣ | ១១.៣៤ |
| | | ១១.៣៥ | ១១.៣៦ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការនិងការប្រកាសពីវត្តមានរបស់ភាគី</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោម សាលសវនាការ។

**<u>សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ</u>**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**<u>ការតាំងសំណួរទៅកាន់សាក្សី មុយ វ៉ាន់នី (2-TCW-987)</u>**

មេធាវីការពារក្តី ខៀវ សំផន បានតាំងសំណួរទៅកាន់សាក្សី មុយ វ៉ាន់នី (2-TCW-987)។

**<u>ការតាំងសំណួរទៅកាន់សាក្សី សយ ឌឿន (2-TCW-988)</u>**

សហព្រះរាជអាជ្ញា មេធាវីការពារក្តី នួន ជា និងមេធាវីការពារក្តី ខៀវ សំផន បានតាំងសំណួរទៅកាន់សាក្សី សយ ឌឿន (2-TCW-988)។

**<u>សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំប្រើប្រាស់ឯកសារ E319/19.3.226 នៅក្នុងសវនាការ</u>**

សហព្រះរាជអាជ្ញាបានស្នើសុំដាក់បង្ហាញឯកសារ E319/19.3.226 ទៅកាន់សាក្សី 2-TCW-988 ដើម្បីឱ្យដឹងថាតើសាក្សី 2-TCW-988 ស្គាល់បុគ្គលដែលមានឈ្មោះនៅក្នុងឯកសារនោះដែរឬទេ ដែលថាបុគ្គលនោះជាសមាជិកនៅក្នុងក្រុមដាវវែង។ មេធាវីការពារក្តី ខៀវ សំផន បានជំទាស់ទៅនឹងការបង្ហាញឯកសារនេះ ដោយសារសំណើសុំឱ្យទទួលយកឯកសារនេះធ្វើជាភ័ស្តុតាង ដែលបានស្នើដោយសហព្រះរាជអាជ្ញាកាលពីថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៥ គឺមិនទាន់បានសម្រេចដោយអង្គជំនុំជម្រះនៅឡើយ។ សហព្រះរាជអាជ្ញាប្រកាន់ជំហរថាឯកសារនេះមានសារប្រយោជន៍ក្នុងការឱ្យសាក្សី 2-TCW-988 មើលឈ្មោះដែលមាននៅក្នុងឯកសារនោះ ដើម្បីឱ្យសាក្សីបញ្ជាក់ព័ត៌មាននោះ។ ចៅក្រម Lavergne និង ចៅក្រម Fenz បានបញ្ជាក់ថាការបង្ហាញឈ្មោះដែលមាននៅក្នុងឯកសារនោះទៅកាន់សាក្សី 2-TCW-988 មិនមែនជាការទទួលយកឯកសារនោះជាភ័ស្តុតាងឡើយ។ មេធាវីការពារក្តី ខៀវ សំផន មិនជំទាស់លើការបង្ហាញឈ្មោះទៅកាន់សាក្សី 2-TCW-988 នោះទេ ប៉ុន្តែបានបញ្ជាក់ថាការធ្វើដូច្នេះ គឺមិនអាចជាសំអាងហេតុនៃសេចក្តីសម្រេចនៅចំពោះមុខអង្គជំនុំជម្រះឡើយ។ អង្គជំនុំជម្រះបានទទួលយកឯកសារ E319/19.3.226 ជាឯកសារភ័ស្តុតាង ដោយសំអាងហេតុនៃសេចក្តីសម្រេចនេះនឹងផ្តល់ជូនពេលក្រោយ។

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភ័ស្តុតាង</u>**

Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/9660 | E319/19.3.95 | 01007903-01007909, 01044595 - 01044602, 01118054-01118060 | Written Record of Interview of SÂY Doeun | C | 01007907, 01007908 | 01044599,01044600, | 01118057, 01118058 |
| E3/3861 | | 00009213-00009218, 00657714-00657726, 00634431-00634443 | List of Prisoners 'smashed' 8-7-77 North Zone | P | 00009215 | 00657716 | 00634431 |
| E3/9346 | | 00235013-00235017, | Written Record of | P | 00235016 | 00235508 | 00283948 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | 00235509, 00283945-00283949 | SÂMRET Muy | | | | |
| E3/9654 | E319/19.3.226 | 01023118-01023124, 01044612-01044620, 01120102-01120107 | Written Record of Interview of [REDACTED] | C | / | / | / |
| E3/5257 | | 00243099-00243109, 00251012-00251022 , 00342661-00342675, | Written Record of Interview of TAY Kimhuon | P | 00243104 | 00251017 | 00342670 |
| E1/346.1 | | 01146147-01146238, 01145917-01146022, 01146023-01146146 | Transcript of hearing on the substance in Case 002/02 - 14 September 2015 | P | / | / | / |
| E1/345.1 | | 01142261-01142291, 01142425-01142459, 01142387-01142424 | Transcript of hearing on the substance in Case 002/02 - 10 September 2015 | P | / | / | / |

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.០៧)
- សេចក្តីសម្រេចទទួលយកឯកសារ ជាឯកសារភ័ស្តុតាង ដោយសំអាងហេតុនៃសេចក្តីសម្រេចនេះនឹងផ្តល់ជូនពេលក្រោយ។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញឱ្យបានមុនម៉ោង ៩.០០ ព្រឹក នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦។ (១៥.៣២)

| <u>**កាលវេលាសវនាការបន្ត**</u> |
| --- |
| សវនាការនឹងបន្តទៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦ ចាប់ផ្តើមពីម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៦

ក្រឡាបញ្ជី ក្រឡាបញ្ជី

**ជា ស៊ុទហ៊ាង** Evelyn CAMPOS SANCHEZ